**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

៳៳ ❖ ៳៳

ក្រសួងអប់រំ យុវជន និងកីឡា

លេខ : ១១៧៦ **អយក.ប្រក**

# ប្រកាស

ស្តីពី ការប្តូរឈ្មោះសាលាបឋមសិក្សា អន្លង់ស្នួក

មកជាសាលាបឋមសិក្សា ខៀវ ង៉ែតអែម អន្លង់ស្នួក

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញព្រះរាជក្រឹត្យលេខនស-រកត ១១៩៨-៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស-រកម ០១៩៦-០១ ចុះថ្ងៃទី ២៤ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញអនុក្រឹត្យលេខ២១អនក្រ.បក ចុះថ្ងៃទី២៣ ខែមិនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងអប់រំយុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ១០៤ អនក្រ-បក ចុះថ្ងៃទី១៤ ខែ តុលា ឆ្នាំ ២០០២ ស្តីពីការកែសំរួលរចនាសម្ព័ន្ធនាយកដ្ឋានបឋមនិងមត្តេយ្យសិក្សា ជានាយកដ្ឋានបឋមសិក្សា និង នាយកដ្ឋានអប់រំកុមារតូច
- បានពិនិត្យលិខិតរបស់គណៈកម្មការទ្រទ្រង់សាលាបឋមសិក្សា **អន្លង់ស្នួក** ចុះថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០០២ ដោយមានចំណារឯកភាព របស់ មន្ទីរអប់រំយុវជន និងកីឡាខេត្ត **កំពត** ចុះថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០០៣
- តាមយោបល់ឯកភាពរបស់ **នាយកដ្ឋានបឋមសិក្សា**

## សំរេច

<u>**ប្រការ១**</u> : ប្តូរឈ្មោះសាលាបឋមសិក្សា **អន្លង់ស្នួក** មកជា សាលាបឋមសិក្សា **ខៀវ ង៉ែតអែម អន្លង់ស្នួក** វិញដែលមានទីតាំងស្ថិតនៅ ភូមិស្នួក ឃុំ **សំឡាញ** ស្រុក **អង្គរជ័យ** ខេត្ត **កំពត** ចាប់ពីឆ្នាំសិក្សា ២០០៣-២០០៤ នេះតទៅ ។

<u>**ប្រការ២**</u> : បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍ ។

<u>**ប្រការ៣**</u> : អគ្គនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានបឋមសិក្សា នៃក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និងកីឡា ខេត្ត **កំពត** ការិយាល័យអប់រំ យុវជន និងកីឡាស្រុក **អង្គរជ័យ** នាយកសាលាបឋមសិក្សា **ខៀវ ង៉ែតអែម អន្លង់ស្នួក** មានភារកិច្ចអនុវត្តប្រកាសនេះ ។

ភ្នំពេញ , ថ្ងៃទី ... ខែ ... ឆ្នាំ ២០០៣

**ជ.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា**

**រដ្ឋលេខាធិការ**

**អ៊ឹម សេធី**

**កន្លែងទទួល**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងផែនការ - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- សាលាខេត្ត **កំពត**

<u>**"ដើម្បីជូនជ្រាបជាពត៌មាន"**</u>

- ដូចប្រការ ៣
- កាលប្បវត្តិ-ឯកសារ នា បស